សុន្ទរកថាគន្លឹះរបស់

**ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

ក្នុងឱកាសអបអរសាទរទិវា "ASEM DAY" ក្រោមប្រធានបទ៖

«កម្ពុជាឆ្ពោះទៅកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ ឆ្នាំ២០២០ និងគោលនយោបាយ

ការបរទេសកម្ពុជាក្នុងបរិបទសកលបច្ចុប្បន្ន»

ភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩

*******

*– ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា*

*– ឯកឧត្តម **ឯកអគ្គរដ្ឋទូត** Karsten WARNECKE នាយកប្រតិបត្តិនៃមូលនិធិអាស៊ី-អឺរ៉ុប*

*– ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី*

*– លោកគ្រូ អ្នកគ្រូ និងក្មួយៗនិស្សិតជាទីមេត្រី*

១. ខ្ញុំមានសេចក្ដីសោមនស្សរីករាយ និងកិត្តិយសក្រៃលែងដែលបានចូលរួមជាអធិបតីក្នុងពិធីប្រារព្ធទិវានៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM DAY) នៅឆ្នាំនេះ។

២. ក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះចំពោះក្រសួងអប់រំយុវជន និងកីឡា ដែលបានសហការរៀបចំ និងសម្របសម្រួលការចូលរួមរបស់ក្មួយៗនិស្សិត និងសាស្ត្រាចារ្យមកពីបណ្ដាសាកលវិទ្យាល័យនានាក្នុងកម្មវិធីនេះ។ នេះគឺជាលើកទី៣ហើយដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសហការជាមួយក្រសួងអប់រំយុវជន និងកីឡា រៀបចំព្រឹត្តិការណ៍ពាក់ព័ន្ធនឹងកិច្ចប្រជុំអាស៊ី-អឺរ៉ុប ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណៈជននៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងចំណោមមន្ត្រីរាជការ និងនិស្សិតសាកលវិទ្យាល័យនានា។

៣. ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះឯកឧត្តម **ឯកអគ្គរដ្ឋទូត** Karsten WARNECKE នាយកប្រតិបត្តិនៃមូលនិធិអាស៊ីអឺរ៉ុប (ASEF) ដែលបានចូលរួមក្នុងកម្មវិធីនាព្រឹកនេះ។ នៅរសៀលនេះ នៅទីស្ដីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម **ឯកអគ្គរាជទូត** Karsten ក៏នឹងចូលរួមចែករំលែកបទពិសោធន៍ និងមេរៀនកន្លងមករបស់គាត់ដល់មន្ត្រីក្រសួង/ស្ថាប័នពាក់ព័ន្ធ អំពីការរៀបចំព្រឹត្តិការណ៍អមកិច្ចប្រជុំកំពូល (ASEM Side Events) ដែលកម្ពុជាមានកិត្តិយសនឹងធ្វើជាម្ចាស់ផ្ទះទទួលរៀបចំកិច្ចប្រជុំកំពូល

អាស៊ី-អឺរ៉ុប នៅឆ្នាំ២០២០ ខាង មុខ។ ហេតុដូចនេះហើយ បានជាខ្ញុំជ្រើសរើសយកប្រធានបទសម្រាប់ថ្ងៃនេះគឺ «**កម្ពុជាឆ្ពោះទៅកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ នៅឆ្នាំ២០២០**»។

## ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗនិស្សិត

៤. អ្នកមួយចំនួនប្រហែលជាមានការងឿងឆ្ងល់ថា ហេតុអ្វីបានជាយើងទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ នៅឆ្នាំក្រោយនេះ? ហើយកិច្ចប្រជុំកំពូលនេះ មានសារៈសំខាន់ដូចម្ដេចខ្លះ? ខ្ញុំសូមលើកយកនូវចំណុចសំខាន់ៗមួយចំនួន មកបង្ហាញជូនដូចតទៅ៖

៥. ជាបឋមនេះគឺ កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) ត្រូវបានចាត់ទុកជាវេទិកាក្រៅផ្លូវការតែមួយគត់សម្រាប់កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការរវាងទ្វីបអាស៊ី និងអឺរ៉ុប ដែលផ្ដោតលើការពង្រឹងភាព ជាដៃគូជំរុញឲ្យមានសន្តិភាព និងសន្តិសុខ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយ ចីរភាព។ កិច្ចប្រជុំអាស៊ី-អឺរ៉ុបនេះ មានវិសាលភាពគ្របដណ្ដប់លើទិដ្ឋភាពនយោបាយ និងសន្តិសុខ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងទិដ្ឋភាពវប្បធម៌-សង្គម ហើយយន្តការនេះក៏ជាវេទិកាដ៏ល្អប្រសើរសម្រាប់ថ្នាក់ដឹកនាំដោះស្រាយបញ្ហាប្រឈមសកលនានាផងដែរ។

៦. ចាប់តាំងពីកិច្ចប្រជុំកំពូលលើកដំបូងនៅខែមីនា ឆ្នាំ១៩៩៦ នៅទីក្រុងបាងកក ដែលមានរដ្ឋស្ថាបនិកត្រឹមតែ ២៦ វេទិកានេះបានពង្រីកសមាជិកភាពរបស់ខ្លួនដល់ទៅ ៥៣ ប្រទេស និងដៃគូ។ បូកបញ្ចូលគ្នាទៅវេទិកា ASEM នេះ បានតំណាងឲ្យប្រមាណ៦៥%នៃសេដ្ឋកិច្ចពិភពលោក, ៦០%នៃប្រជាជន, ៥៥%នៃពាណិជ្ជកម្ម និង៧៥%នៃទេសចរណ៍ពិភពលោក ។

៧. កម្ពុជាយើងបានចូលរួមក្នុងយន្តការនេះចាប់តាំងពីកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី៥ នាឆ្នាំ២០០៤ នៅប្រទេសវៀតណាម មកម្លេះ ដែលយើងចាត់ទុកកិច្ចប្រជុំអាស៊ី-អឺរ៉ុប ជាវេទិកាដ៏សំខាន់មួយសម្រាប់កិច្ចសហប្រតិបត្តិការរវាងតំបន់ និងតំបន់ ដែលផ្ដល់ផលប្រយោជន៍ជាច្រើនដល់កម្ពុជា។ **<u>ទីមួយ</u>:** កិច្ចប្រជុំអាស៊ី-អឺរ៉ុបផ្ដល់ឲ្យកម្ពុជានូវឱកាសល្អក្រៃលែង ដើម្បីលើកកម្ពស់មុខមាត់របស់ខ្លួននៅលើឆាកអន្តរជាតិ។ **<u>ទីពីរ</u>:** វេទិការនេះផ្ដល់ឱកាសដល់កម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា ជាមួយសមាជិកដទៃទៀត តាមរយៈកិច្ចប្រជុំកំរិតខ្ពស់នានានៃដំណើរការរបស់ ASEM និងជំរុញកិច្ចសហប្រតិបត្តិការលើវិស័យជាក់លាក់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា រួមមានការផ្លាស់ប្ដូរពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងវប្បធម៌ជាដើម។ **<u>ទីបី</u>:** កិច្ចប្រជុំអាស៊ី-អឺរ៉ុប បានរួមចំណែកលើកស្ទួយការអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជាទាំងក្នុងវិស័យសាធារណៈ និងឯកជន។ **<u>ទីបួន</u>:** ការតភ្ជាប់នៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប គឺជាទិដ្ឋភាពដ៏រស់រវើកបំផុតសម្រាប់កម្ពុជា ដើម្បីការលើក កំពស់ការផ្លាស់ប្ដូររវាងប្រជាជន និងប្រជាជន នៅក្នុងបរិបទដែលតំបន់អាស៊ី-អឺរ៉ុប កំពុងតែមានការតភ្ជាប់គ្នាកាន់តែខ្លាំងឡើងៗ។

៨.	ជាច្រើនឆ្នាំមកនេះ កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនានានៃដំណើរការរបស់ ASEM។ ជាក់ស្តែង កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៃព្រឹត្តិការណ៍ ASEM ចំនួនពីរ បន្ថែមលើព្រឹត្តិការណ៍ថ្ងៃនេះ ដែលរួមមាន *«វគ្គបណ្តុះបណ្តាលលើកទី៧ (7th Face-to-Face Training) ក្រោមគំនិតផ្តួចផ្តើមនៃវគ្គបណ្តុះបណ្តាលការទូតអាស៊ី-អឺរ៉ុប »* និង *«កិច្ចសន្ទនាស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុបលើកទី៨ ក្រោមប្រធានបទ៖ ការលើកកម្ពស់ភាពជាដៃគូទឹក ដើម្បីកំណើន និងការអភិវឌ្ឍប្រកបដោយចីរភាព»*។ មានសកម្មភាព និងព្រឹត្តិការណ៍ជាច្រើនដែល បណ្តាប្រទេសជាសមាជិក ASEM ផ្សេងទៀតកំពុងធ្វើជាម្ចាស់ផ្ទះ ដែលភាគច្រើនយើងមានគណៈប្រតិភូកម្ពុជាយើងចូលរួម ។

៩.	នៅខែធ្នូ ឆ្នាំនេះ ខ្ញុំនឹងដឹកនាំគណៈប្រតិភូកម្ពុជាទៅចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុបលើកទី១៤ នៅប្រទេស	អេស្ប៉ាញ។

## ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗនិស្សិត

១០.	ហេតុអ្វីបានជាយើងសំរេចចិត្តទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ**កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣** នៅប្រទេសកម្ពុជាយើង ក្នុងឆ្នាំ២០២០ ខាងមុខ? ការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប គឺឈរលើគោលការណ៍ស្ម័គ្រចិត្ត និងប្តូរវេនគ្នារៀងរាល់២ឆ្នាំម្តង ដោយម្តងធ្វើនៅអាស៊ី និងម្តងត្រូវធ្វើនៅអឺរ៉ុប។ កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកចុងក្រោយ បានធ្វើឡើងនៅក្នុងខែតុលា ឆ្នាំ២០១៨ នៅទីក្រុងប្រ៊ុចសែល ដែលនៅពេលនោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានប្រកាសជាផ្លូវការពីការទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣។ ការប្រកាសនេះ បានទទួលការផ្តល់តម្លៃ និងអបអរសាទរជាខ្លាំងពីថ្នាក់ដឹកនាំ ASEM ទាំងអស់។

១១.	និយាយដោយស្មោះត្រង់ទៅ វាពិតជាភារកិច្ចប្រកបដោយមហិច្ឆតាដែលយើងទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលដ៏ធំបែបនេះ ពីព្រោះថានឹងមានការចូលរួមពីថ្នាក់ដឹកនាំកំពូលដល់ទៅ ៥៣រូប។ ប្រាកដណាស់ កិច្ចប្រជុំនេះត្រូវការប្រេកពធនជានច្រើនដើម្បីដោះស្រាយការប្រឈមក្នុងការរៀបចំ ដូចជា បញ្ហាថវិកា ធនធានមនុស្ស ការផ្គត់ផ្គង់ផ្នែកបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិធីការ កំរិតខ្ពស់ និងបញ្ហាសន្តិសុខដ៏ល្អិតល្អន់បំផុត ។ល។

១២. ប៉ុន្តែយើងក៏ទទួលស្គាល់ដែរថា ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះ កម្ពុជាយើងក៏នឹងបានប្រយោជន៍មកវិញច្រើនផងដែរ។ កិច្ចប្រជុំកំពូលនេះនឹងក្លាយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏ធំបំផុត មិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រសម័យថ្មីរបស់កម្ពុជា។ វាពិតជាកិត្តិយសដ៏វិសេសវិសាលខ្លាំងណាស់សម្រាប់ជាតិយើង។ ច្បាស់ណាស់ថា យើងធ្លាប់មានបទពិសោធន៍ក្នុងការរៀបចំដោយជោគជ័យ នូវកិច្ចប្រជុំកំពូលថ្នាក់តំបន់ និងអនុតំបន់ជាច្រើន ដូចជាកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០០២ និងឆ្នាំ២០១២ ជាដើម ប៉ុន្តែវាមិនមានទ្រង់ទ្រាយធំ

ដូចកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប នាលើកនេះឡើយ។ ក្នុងឋានៈជារដ្ឋាភិបាលមួយ ជាប្រជាជាតិមួយ យើងទាំងអស់គ្នាប្តេជ្ញាចិត្តថានឹងខិតខំឲ្យអស់ពីសមត្ថភាព ដើម្បីជានាឲ្យកិច្ចប្រជុំកំពូលនេះ ដំណើរការទៅដោយរលូន និងទទួលបានជោគជ័យ។

១៣. សំខាន់ជាងនេះទៅទៀត ការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលនេះ គឺជាឱកាសដ៏ល្អក្រៃលែង ដើម្បីបញ្ជាក់នូវតួនាទីរបស់កម្ពុជាក្នុងការចូលរួមក្នុងកម្រិតខ្ពស់បំផុតនៅលើឆាកអន្តរជាតិ។ វាក៏ជាការបង្ហាញនូវការចូលរួមយ៉ាងសកម្មរបស់កម្ពុជា នៅក្នុងក្របខណ្ឌនៃកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប ដោយឈរលើមូលដ្ឋាននៃភាពជាដៃគូស្មើភាពគ្នា ជាមួយនឹងសមាជិកទាំងអស់។ នេះក៏បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តបន្តទៀតរបស់កម្ពុជា តាមរយៈដំណើរការនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប ដើម្បីដោះស្រាយបញ្ហាសកលនាពេលបច្ចុប្បន្ន និងរិះរកកាលានុវត្តភាពដើម្បីពង្រឹងបន្ថែមនូវកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសដៃគូអាស៊ី-អឺរ៉ុប និងប្រទេសដៃគូជាច្រើនផ្សេងទៀត។

១៤. ក្នុងនាមជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលនេះ កម្ពុជាយើងគ្រោងនឹងរៀបចំព្រឹត្តិការអមចំនួន ៧ ដែលជាការអនុវត្តតាមទម្លាប់នៃដំណើរការរបស់ASEM ក្នុងនោះរួមមាន៖ ១. កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប ២. បុណ្យវប្បធម៌អាស៊ី-អឺរ៉ុប ៣. វេទិកាសេដ្ឋកិច្ច និងធុរកិច្ចអាស៊ី-អឺរ៉ុប ៤. កិច្ចប្រជុំកំពូលថ្នាក់ដឹកនាំវ័យក្មេងនៃមូលនិធិអាស៊ី-អឺរ៉ុប ៥. កិច្ចពិភាក្សាតុមូលក្រុមនិពន្ធសារព័ត៌មាននៃមូលនិធិអាស៊ី-អឺរ៉ុប ៦. វេទិកាការងារអាស៊ី-អឺរ៉ុប និង ៧. វេទិកាប្រជាជនអាស៊ី-អឺរ៉ុប។

១៥. ហេតុដូច្នេះហើយ បានជាខ្ញុំមានការរីករាយដែលឃើញវត្តមានតំណាងជាច្រើនមកពីស្ថាប័នផ្សេងៗ ដូចជាស្ថាប័នសភា សារព័ត៌មាន សង្គមស៊ីវិល និងវិស័យឯកជន ជាពិសេសយុវជន-យុវនារី ដែលបានមកចូលរួមកម្មវិធីនេះ។ យើងត្រូវការឲ្យមានការចូលរួមរបស់អ្នកទាំងអស់គ្នា ដើម្បីធ្វើឲ្យកិច្ចប្រជុំ កំពូលរបស់យើងនាឆ្នាំក្រោយទទួលបានជោគជ័យ។

១៦. ខ្ញុំសូមគូសបញ្ជាក់ថា គោលបំណងនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុបនេះ ស្របនឹងគោលនយោបាយការបរទេសកម្ពុជាយើង នោះគឺការថែរក្សា និងជំរុញនូវសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងន័យនេះ ខ្ញុំសូមលើកមកបង្ហាញជូននូវផ្នែកទីពីរនៃប្រធានបទព្រឹកនេះស្តីអំពី «នយោបាយការបរទេសកម្ពុជាក្នុងបរិបទសកលលោកបច្ចុប្បន្ន»។

## ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗនិស្សិត

១៧. ឆ្នាំ ២០១៩ និងបណ្តាឆ្នាំតទៅមុខ ស្ថានការណ៍ពិភពលោកនឹងបន្តប្រែប្រួលយ៉ាងជ្រាលជ្រៅ ស្មុគស្មាញ ឆាប់រហ័ស និងពិបាកប៉ាន់ស្មានបាន។

១៨. ដំណើរប្រែប្រួលទៅកាន់ប្រព័ន្ធពហុប៉ូលនៅបន្តទៅមុខ។ ការងើបឡើងកាន់តែជាក់ច្បាស់របស់តួអង្គថ្មីៗ នៅលើឆាកអន្តរជាតិ នឹងទាញការទទួលខុសត្រូវក្នុងការចាត់ចែងកិច្ចការពិភពលោកទៅរកប៉ូលថ្មី បង្កើតជាការប្រកួតប្រជែងជាយុទ្ធសាស្ត្រ ដើម្បីអំណាច ឥទ្ធិពល និងផលប្រយោជន៍។

១៩. ការងាកចេញរបស់មហាអំណាចទី ១ ពីប្រព័ន្ធពហុភាគីនិយម ទៅកាន់ឯកតោភាគីនិយម និងគាំពារនិយម កំពុងគំរាមដល់ប្រព័ន្ធសណ្តាប់ធ្នាប់ពិភពលោកបច្ចុប្បន្ន ដែលជាវិធានសម្រាប់ចាត់ចែងទំនាក់ទំនងអន្តរជាតិ អស់កាលជាង៧០ឆ្នាំមកហើយ។

២០. ភ្នក់ជម្លោះតាមតំបន់នានានៅមជ្ឈិមបូព៌ា អឺរ៉ុបខាងកើត អាហ្វ្រិក អាមេរិកឡាទីន និងនៅអាស៊ី បញ្ហាប្រឈមធ្ងន់ធ្ងរ តួយ៉ាង អំពើភេរវកម្ម វិបត្តិជនភៀសខ្លួន ឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យា ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស / គ្រឿងញៀន ការប្រែប្រួលធាតុអាកាស និងបញ្ហាបរិស្ថាន ជំងឺឆ្លង និងគ្រោះធម្មជាតិ។ល។ នឹងនៅតែបន្តគំរាមកំហែងដល់សន្តិសុខពិភពលោក និងត្រូវការការរួមកម្លាំងទាំងអស់គ្នា ដើម្បីឆ្លើយតបដោះស្រាយ។

២១. តំបន់អាស៊ី-ប៉ាស៊ីហ្វិក នឹងនៅតែជាចំណុចកណ្តាលនៃការប្រកួតប្រជែងរបស់មហាអំណាចធំៗ។ ការងើបឡើងរបស់បណ្តាប្រទេសនៅអាស៊ី នាំមុខដោយ ចិន ជប៉ុន ឥណ្ឌា កូរ៉េខាងត្បូង និងអាស៊ាន កំពុងធ្វើឲ្យជញ្ជីងអំណាចផ្អៀងពីភាគខាងលិច មកភាគខាងកើត។

២២. អាស៊ាននឹងបន្តជាគម្រូនៃសមាហរណកម្មប្រកបដោយជោគជ័យផង ជាកម្មវត្ថុនៃការចង់ភ្ជាប់ភាពជាដៃគូជាមួយផង និង  ក៏ជាកន្លែងដែលទទួលរងឥទ្ធិពល និងសម្ពាធពីការប្រកួតប្រជែងនោះផង។

២៣. កម្ពុជាយើង ក៏ដូចជាប្រទេសតូចធំនានា ក្នុងតំបន់ និងពិភពលោក នឹងបន្តទទួលរងផលប៉ះពាល់ពីឥទ្ធិពល និងសម្ពាធ ដែលកើតចេញពីការប្រកួតប្រជែងកាន់តែតានតឹងឡើងរបស់មហាអំណាចធំៗ។

២៤.  កម្ពុជាយើង កំពុងរីករាយជាមួយនឹងកំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា និងស្ថិរភាពនយោបាយរបស់ខ្លួន។ កត្តាទាំងពីរនេះ គឺជាធាតុសំខាន់បំផុតដើម្បីជួយយើងនៅក្នុងការដោះស្រាយ និងជម្នះនូវនិន្នាការ និងការគំរាមកំហែងនៅក្នុងតំបន់ និងសកលោក។ ខ្ញុំតែងរំលឹកថា ប្រទេសកម្ពុជា គឺជារដ្ឋតូចមួយ។ យើងមិនអាចផ្លាស់ប្តូរឋានៈនេះបានឡើយ ប៉ុន្តែយើងអាចមានភាពឆ្លាតវៃ និងបុរេសកម្មដើម្បីបន្តបត់បែនសម្របខ្លួនទៅនឹងតថភាពនយោបាយថ្មី ដោយផ្អែកលើឆន្ទៈ សមត្ថភាព និងផលប្រយោជន៍ស្នូលរបស់យើង។

២៥.  ខ្ញុំសូមចែករំលែកជាមួយអ្នកទាំងអស់គ្នា នូវទស្សនវិស័យមួយចំនួនទាក់ទងនឹងគោលនយោបាយការបរទេសរបស់យើង នៅក្នុងបរិការពិភពលោកបច្ចុប្បន្ននេះ ដូចតទៅ៖

**តម្លៃស្នូលទីមួយរបស់យើង គឺការការពារផលប្រយោជន៍គោលរបស់ជាតិ ជាពិសេស ការការពារឯករាជ្យ និងអធិបតេយ្យភាពរបស់យើង។**

២៦. ការងារនេះបានក្លាយជាអាទិភាពចម្បង ក្នុងការងារការទូតរបស់យើង ក្នុងបរិបទនៃការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ការដាក់សម្ពាធកៀបសង្កត់ យកធន្ទៈប្រទេសធំមកបង្ខំឲ្យយើងទទួល ដែលនេះគំរាមយ៉ាងធ្ងន់ធ្ងរដល់ឯករាជ្យ អធិបតេយ្យភាព ក៏ដូចជាគំរាមសន្តិភាព និងស្ថិរភាពរបស់ប្រទេសជាតិ។ កម្ពុជាតែងតែអរគុណប្រទេស និង ស្ថាប័នទាំងអស់ដែលបានជួយឧបត្ថម្ភគាំទ្រដោយស្មោះ ការស្តារ និងកសាងជាតិឡើងវិញកន្លងមក។ រហូតមកទល់សព្វថ្ងៃនេះ យើងនៅបន្តទទួលផលពីសមានចិត្ត និងការជួយឧបត្ថម្ភគាំទ្រនេះពីប្រទេសជាច្រើននៅតំបន់អាស៊ី អាមេរិក និងអឺរ៉ុប តាមរូបភាពផ្សេងៗគ្នា តួយ៉ាងជំនួយឥតសំណង កម្ចីដោយការប្រាក់សម្បទាន ការអនុគ្រោះពន្ធលើទំនិញនាំចូលពីប្រទេសកម្ពុជាយើង ដូចរបបអនុគ្រោះពន្ធក្រោមកម្មវិធី EBA នេះជា ដើម។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ផ្អែកលើមេរៀននៃសោគនាដកម្មពីអតីតកាល ដែលបានកើតចេញពីការបាត់បង់ឯករាជ្យ អធិបតេយ្យភាពជាតិនេះ កម្ពុជាមិនអនុញ្ញាតដាច់ខាតឲ្យប្រវត្តិសាស្ត្រជាន់ដានឯងនោះម្តងទៀតឡើយ។ យើងនឹងមិនប្តូរអធិបតេយ្យភាពរបស់យើងជាមួយនឹងជំនួយណាជាដាច់ខាត។ យើងត្រូវបន្តការពារនូវសិទ្ធិអធិបតេយ្យរបស់យើង ក្នុងការធ្វើសេចក្តីសម្រេចដោយឯករាជ្យ ដើម្បីការពារប្រយោជន៍គោលរបស់ជាតិយើង ការពារសន្តិភាព ភាពសុខសាន្តរបស់ប្រជាជន ប្រឆាំងតបនឹងរាល់ការប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ដែលកើតចេញពីធន្ទៈ និងការគាំទ្ររបស់ប្រជាជនភាគច្រើនលើសលុប។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគ្រប់ស្ថានបេសកកម្មរបស់យើងនៅក្រៅប្រទេស បានតាំងចិត្តប្តេជ្ញាក្នុងការតស៊ូដើម្បីការពារយុត្តិធម៌ជូនរាជរដ្ឋាភិបាល ជូនប្រទេសជាតិ និងប្រជាជនកម្ពុជាយើង។

**តម្លៃស្នូលទីពីររបស់យើងគឺត្រូវធានាថា គោលនយោបាយការបរទេសរបស់យើងនៅតែរឹងមាំ និងហើយការងារការទូតរបស់យើងអាចបត់បែនបាន ដើម្បីឆ្លើយតបទៅនឹងសក្តានុពលនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ ក្នុងចំណោមមហាអំណាច។**

២៧. នៅចំពោះមុខសភាពការណ៍តំបន់ និងពិភពលោកដែលកំពុងវិវត្តប្រែប្រួលយ៉ាងឆាប់រហ័ស ស្មុគស្មាញមិនអាចប៉ាន់ស្មានបាន និងប្រកបដោយគ្រោះថ្នាក់នោះ ការកាច់ចង្កូតនាវាកម្ពុជា ទាមទារ ការថ្លឹងថ្លែង និងការប្រុងប្រយ័ត្នខ្ពស់។ ត្រង់នេះហើយដែលការអនុវត្តនូវនយោបាយការបរទេសប្រកបដោយភាពបត់បែនរៀងវៃ តបទៅនឹងការប្រែប្រួល និងសម្ពាធភូមិសាស្ត្រនយោបាយ និងការប្រកួតប្រជែងដ៏តានតឹងរបស់មហាអំណាចនានានោះ មានសារៈសំខាន់បំផុតដើម្បីរក្សាឲ្យបាននូវលក្ខខណ្ឌចាំបាច់នានា ដើម្បីការពារសន្តិភាព ស្ថិរភាព ដំណើរអភិវឌ្ឍន៍ប្រទេសជាតិ ដោយឈរលើគោលការណ៍អព្យាក្រឹត្យអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។

២៨. គោលនយោបាយក្នុងស្រុក និងគោលនយោបាយការបរទេស បំពេញឲ្យគ្នាទៅវិញទៅមក ហើយមានទំនាក់ទំនងមិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ។ អនុវត្តតាមបាវចនាពីររបស់រាជរដ្ឋាភិបាល ពោលគឺ «កែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅ ក្នុងស្មារតីពង្រឹងឯករាជ្យ និងអធិបតេយ្យភាពជាតិ» យើងនឹងបន្តបង្កើនទំនាក់ទំនង និងសកម្មភាពការទូតដើម្បីពង្រឹង និងពង្រីកចំណងមិត្តភាព និងសហប្រតិបត្តិការជាមួយប្រទេសនានានៅលើលោកឲ្យកាន់តែច្រើនថែមទៀត ដើម្បីលើកស្ទួយផលប្រយោជន៍ និងកិត្យានុភាពជាតិកម្ពុជា។

**តម្លៃស្នូលទីបីរបស់យើង គឺត្រូវលើកកម្ពស់ការទូតសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងការទូត វប្បធម៌ ដើម្បីជានាបាននូវប្រភពបន្ថែមសម្រាប់កំណើន តាមរយៈការធ្វើពិពិធកម្មដើម្បីពង្រឹងសេដ្ឋកិច្ច ជាតិរបស់យើង។**

២៩. មានបាវចនៈមួយដែលមេដឹកនាំ ឥស្សរជន វាគ្មិននានាបានលើកឡើងនៅគ្រប់វេទិកាទាំងអស់ នោះគឺ **«គ្មានទេការអភិវឌ្ឍ ប្រសិនបើគ្មានសន្តិភាព ហើយក៏គ្មានសន្តិភាពយូរអង្វែងដែរ ប្រសិនបើគ្មានការអភិវឌ្ឍ»** ព្រោះនេះជាតថភាពជាក់ស្តែង។ គោលនយោបាយការបរទេសរបស់យើង គឺចាត់ទុកវិបុលភាពសេដ្ឋកិច្ចជាផលប្រយោជន៍ស្នូលរបស់ប្រជាជនយើង។

៣០. ការផ្លាស់ប្តូរពីរបៀបធ្វើការងារការទូតប្រពៃណី មកជាការងារការទូតដែលផ្តោតសារៈសំខាន់ដល់ការលើកស្ទួយសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ គឺជាការឆ្លើយតបយ៉ាងត្រឹមត្រូវទៅនឹងសភាពការណ៍ថ្មីដែលទាមទារឲ្យអ្នកការទូតយើង រួមវិភាគទានកាន់តែធំដល់ការជំរុញសេដ្ឋកិច្ច និងវិនិយោគ ទាក់ទាញទេសចរ និងការផ្សព្វផ្សាយវប្បធម៌ជាតិខ្មែរ។ យើងត្រូវប្រែការប្រឈមទាំងឡាយឲ្យក្លាយជាកាលានុវត្តភាពដើម្បីពង្រឹងខ្លួនឯង រស់ខ្លួនឯង និងអភិវឌ្ឍខ្លួនឯងដោយកាត់បន្ថយការពឹងពាក់លើជំនួយពីខាងក្រៅឲ្យនៅតិចបំផុតតាមតែអាចធ្វើទៅបាន។

**តម្លៃស្នូលទីបួននៃគោលនយោបាយការបរទេសរបស់យើង គឺការរួមវិភាគទានដ៏សកម្មរបស់យើងនៅក្នុងការបន្តរក្សាសន្តិភាព និងដោះស្រាយនូវបញ្ហាប្រឈមសកលនានា។**

៣១. យើងមានមោទនភាពជាខ្លាំង ដោយសារកងកម្លាំងរបស់យើងបានចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពរបស់ អ.ស.ប។ ពីប្រទេស មួយដែលទទួលកងទ័ពមួកខៀវរបស់ អ.ស.ប. កម្ពុជាបានក្លាយជាប្រទេសដែលបញ្ជូនកងកម្លាំងរបស់ខ្លួន ទៅចូលរួមបេសកកម្មថែរក្សាសន្តិភាពរបស់ អ.ស.ប. វិញម្តង។ ដោយគិតចាប់តាំងពីឆ្នាំ២០០៦ មក កម្ពុជាបានបញ្ជូនកងកម្លាំងរបស់ខ្លួនជិត ៦០០០ នាក់ ទៅប្រទេសចំនួន ៨ នៅទ្វីបអាហ្វ្រិក និងនៅមជ្ឈិមបូព៌ា។ ទោះបីជាបេសកកម្មទាំងនេះ ជាការងារដ៏មានគ្រោះថ្នាក់ខ្ពស់ ហើយកងកម្លាំងរបស់យើងខ្លះ បានបូជាជីវិតរបស់ពួកគេក៏ដោយ ក៏កម្ពុជាយើងប្តេជ្ញាបន្តនូវការចូលរួមដ៏សកម្មរបស់ខ្លួនដើម្បីបុព្វហេតុសន្តិភាពពិភពលោក។

៣២. យើងក៏នឹងបន្តរួមវិភាគទានរបស់យើងក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងក្នុងការប្រយុទ្ធដោះស្រាយការប្រឈមនានានៅលើលោក តួយ៉ាងប្រឆាំងនឹងភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការប្រែប្រួលធាតុអាកាស ការជួញដូរគ្រឿងញៀននិងមនុស្ស ជំងឺឆ្លង។ល។

## ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗនិស្សិត

៣៣. មុននឹងបញ្ចប់បទឧទ្ទេសនាមរបស់ខ្ញុំ ខ្ញុំសូមអំពាវនាវឲដល់អ្នកទាំងអស់គ្នា សូមចូលរួមឲ្យបានសកម្មក្នុងការលើកកម្ពស់ការយល់ដឹងជា សាធារណៈអំពីដំណើរការនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប ព្រមទាំងជួយពន្យល់បន្តទៀតថា ការទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលលើកទី១៣ នៅចុងឆ្នាំ ២០២០ ខាងមុខ នឹងរួមចំណែកលើកមុខមាត់ និងកិត្តិយសរបស់ប្រទេសកម្ពុជា នៅលើឆាកអន្តរជាតិ ។

៣៤. ជាចុងក្រោយ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងក្មួយៗនិស្សិត សូមបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរគុណ!**

**-- ចប់ --**